# ធម៌សូត្រនមស្ការ

# ព្រះរតនត្រៃ

# បាលី

# ប្រែជាភាសាខ្មែរ

សម្រាប់សូត្រតាមសម្លេងក្នុងស៊ីឌី

# ថ្វាយគ្រឿងសក្ការៈព្រះត្រ័យរ័ត្ន

ឥមេហិ ទីបធូបា ទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ

អភិបូជយាមិ មាតាបិតា ទីនំ គុណវន្តានញ្ច

មយ្ហញ្ច ទីឃរតំ អត្ថាយ ហិតាយ សុខាយ

**ប្រែ**: ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

# នមស្ការព្រះពុទ្ធរតនៈ

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ប្រែៈ វីកិរិយានមស្ការ ថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ អង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ វិជេយ្យោ

សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ តំ បនមាមិ ពុទ្ធំ

ប្រែៈ ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវ ព្រះអនាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវ សម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។ (ក្រាបថ្វាយបង្គំម្តង)

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា

បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា

ប្រែៈ ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វាន កន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រក័ល្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។ (ក្រាបថ្វាយបង្គំម្តង)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ

សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវ

មនុស្សានំ ពុទ្ធោ ភគវាតិ

ប្រែៈ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវ ញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា៣និងវិជ្ជា៨ និងចរណៈ១៥ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅ

កាន់សុន្ទរស្ថាន គឺអមតមហានិព្វាន ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាន នូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន ទ្រង់ព្រះនាមថាសត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង ទ្រង់ព្រះនាមថាភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

ប្រែះ វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណា មិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យ សច្ចៈនេះ ។

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ

ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

ប្រែៈ ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។ (ក្រាបថ្វាយបង្គំម្តង)

## នមស្ការព្រះធម្មរតនៈ

អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ

ប្រែៈ ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ៨ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជន ដែលប្រាថ្នានូវព្រះនិព្វានឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌ជាធម៌ធ្វើឲ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះ ដោយគោរព ។ (ក្រាបថ្វាយបង្គំម្តង)

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា

បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា

ប្រែ: ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក ក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ

បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ

ប្រែ: ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ព្រះនពលោកុត្តរធម៌មាន៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១ ជាធម៌គឺព្រះអរិយបុគ្គល ទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌គឺព្រះអរិយ

បុគ្គលគប្បីបង្អោនចូលមកទុក ក្នុងខ្លួនដោយអំណាចនៃភាវនា ជាធម៌គឺអ្នកប្រាជ្ញ ទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

**ប្រែ:** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណា មិនមានឡើយ មានតែព្រះធម៌ ជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យ សច្ចៈនេះ ។

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ

ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ

ប្រែ: ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវព្រះធម៌ដ៏ប្រសើរមាន២ប្រការ គឺព្រះបរិយត្តិធម៌និងព្រះនពលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។ (ក្រាបថ្វាយបង្គំម្តង)

# នមស្ការព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ

សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិ

បត្តោ អនាសវោ តំ បនមាមិ សង្ឃំ

ប្រែៈ ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិកិលេស ទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវ កិរិយាសម្រេចដោយគុណ ទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។ (ក្រាបថ្វាយបង្គំម្តង)

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា

បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា

ប្រែៈ ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេច មគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គនិងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គនិងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិនេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ

ប្រែៈ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនពលោកុត្តរធម៌ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង នូវព្រះនិព្វានជាស្ពានក្សេមផុតចាកទុក្ខទាំងពួង ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរ ដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីលសមាធិបញ្ញា ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន៤គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ១ អរហត្តមគ្គ និងអរហត្តផលជាគូ១ បើរាប់រៀងជាបុរសបុគ្គល មាន៨គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ ព្រះសង្ឃទាំងនុ៎ះជាសា

វកនៃព្រះដ៏មានព្រះភាគ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើលោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យ នៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

ប្រែៈ វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណា មិនមានឡើយ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យ សច្ចៈនេះ ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ
យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ប្រែៈ ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃដ៏ប្រសើរមាន២ប្រការ គឺសម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។ (ក្រាបថ្វាយបង្គំម្តង)

## ធម៌សូមបុណ្យកងកុសល

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ

បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ

ប្រែៈ ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី

ខ្ពស់លើសលប់លោកាចារ្យ ។

សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា ពេញពោរស្មើភាព

ដូចជលសាធំទូលាយ ។

សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ ឲ្យចៀសចេញចាកឆ្ងាយ

ក្តីអន្តរាយកុំបីមាន ។

ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន កងបុណ្យរាសីមាន

សូមបានក្សាន្តកុំមានមោះ ។

ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ

ដាក់ដល់ស្ថាននិព្វានហោង ។

# វន្ទាមិ ចេតិយំ

វន្ទា មិ ចេតិយំ សព្វំ សព្វដ្ឋា នេសុ បតិដ្ឋិតំ សារីរិកធា

តុំមហាពោធឹ ពុទ្ធរូបំ សកលំ សទា

ប្រែៈ ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ ព្រមទាំងព្រះសារី

រិកធាតុនៃព្រះពុទ្ធ ។

និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត លំអោនចិត្តបរិសុទ្ធ

លើកកំបង់អញ្ជលី ។

និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី ដែលស្ថិតនៅគ្រប់ទី

ស្ថាននានានោះទាំងអស់ ។

ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់ ដែលតែងតែរំលោះ

រំដោះទុក្ខភ័យអន្តរាយ ។

សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ សត្រូវទោះជិតឆ្ងាយ

សូមឲ្យក្លាយមកជាមិត្ត ។

សូមទាន់ព្រះអរិយ មេត្រិយថ្លៃវិសិដ្ឋ សូមបានឃើញធម៌ពិត

សមដូចចិត្តប្រាថ្នាហោង ។

# សុភមង្គលកថា

ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្ដីចម្រើន ដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ

រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ

សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ

សព្វធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង

សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង

សោត្ថី ហោតុ និរន្តរំ សូមសិរីសួស្ដីចូរមានដល់ខ្ញុំ ឲ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

# ធម៌ផ្សាយមេត្តា

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ

អព្យាបជ្ឈា ហោន្តុ អនិឃា ហោន្តុ ទិឃាយុកា ហោន្តុ

អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា

ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

ប្រែៈ ពួកសត្វទាំងអស់ក្នុងទិសបូព៌ ទិសអាគ្នេយ៍ ទិសទក្សិណ ទិសនិរតី ទិសបស្ចឹម ទិសពាយព្យ ទិសឧត្តរ ទិសឦសាន ទិសខាងក្រោម ទិសខាងលើ សូមឲ្យជាសត្វមិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្ដីសុខជានិច្ច

ពួកសត្វទាំងអស់ សូមកុំមានពៀរនឹងគ្នា សូមឲ្យបានតែសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេច ដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឲ្យជាសុខរៀងទៅ ។

សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្ដីទុក្ខ សូមឲ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលកំពុងដល់នូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលកំពុងដល់នូវសេចក្ដីសោក សូមឲ្យជាសត្វ បាត់សេចក្ដីសោកទៅហោង ។

# ធម៌រំលឹកគុណ

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូមសុខសោភា

រួចពីទុក្ខា ឆ្លងដល់ត្រើយមហា ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតខ្ញុំកើត

កំណើតខ្ញុំមាន មគ្គផលជាស្ពាន ដល់ស្ថានថ្លៃថ្លា ។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧបជ្ឈាយាចារ្យ

គុណញាតិកា ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន ខ្ញុំជូនមគ្គផល

កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត ដល់ឋានផុតទុក្ខ ។

ខ្ញុំសូមសច្ចា សច្ចាំងប្រាថ្នា តំណទៅមុខ សូមមានប្រាជ្ញា

ភ្លឺថ្លាបានសុខ សូមរួចចាកទុក្ខ ដល់និព្វានហោង ៕

# ខមាបនគាថា

យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា យេ

បាណេកេ បមាទេន កាយវាចា មនេហិ វា បុញ្ញំ មេ

អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ វេរិនោ ចា បមុញ្ចន្តុ

សព្វទោសំ ខមន្តុ មេ ។

ប្រែៈ សត្វទាំងឡាយណាមួយ ទោះតូចក្តី ធំក្តី ដែលខ្ញុំបានបៀតបៀនហើយ មួយទៀតសត្វទាំងឡាយណា ពួកខ្លះដែលខ្ញុំបានធ្វើ ទុក្ខបុកម្នេញហើយ ព្រោះសេចក្តីប្រមាទ ភ្លាំងភ្លាត់ដោយកាយវាចាចិត្ត សត្វទាំងឡាយនោះ ចូរអនុមោទនា នូវបុណ្យរបស់ខ្ញុំចុះ ចូរទទួលយកនូវផលបុណ្យ ដ៏ឧត្តមចុះ បើសត្វទាំងឡាយ ដែលមានពៀរនឹងគ្នា ចូររួចរំដោះចាកពៀរនោះចុះ សូមអត់ទោសទាំងពួងដល់ខ្ញុំផង ។

## អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។
អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ រាជា នោ ។
អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ មាតា បិតា រោ ។
អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ
អនុមោទន្តុ ចិរំ រក្ខន្តុ គ្រូឧបជ្ឈា អាចារិយោ ។

អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ

អនុមោទន្តុ ចិរំ រក្ខន្តុ ញាតិយោ ។

អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ

អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។

អាកាសដ្ឋា ច ភូម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ

អនុមោទន្តុ ចិរំ រក្ខន្តុ នោសទា ។

## ជយបរិត្តគាថា

មហាការុណិកា នាថោ ហិតាយ សព្វបាណិនំ បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ អបរាជិតបល្លង្កេ សីសេ បឋវី បោក្ខរេ អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារីសុ បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ

បទក្ខិណំ មនោកម្មំ បណិធិ តេ បទក្ខិណា បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។

## សម្ពុទ្ធេ

សម្ពុទ្ធេ អដ្ឋវិសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ចសតសហស្សានិ នមាមិ សិរសា អហំ តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។

សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិ សហស្សកេ ទសសតសហស្សានិ នមាមិ សិរសា អហំ តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។

សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីស សហស្សកេ វិសតិសតសហស្សានិ នមាមិ សិរសា អហំ តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។

ប្រែះ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ព្រះអង្គផង ១ម៉ឺន២ពាន់ព្រះអង្គផង ៥សែនព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឲ្យកំចាត់បង់ នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥៥ព្រះអង្គផង ២ម៉ឺន៤ពាន់ព្រះអង្គផង ១លានព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា ។ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឲ្យកំចាត់បង់ នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ព្រះអង្គផង ៤ម៉ឺន៨ពាន់ព្រះអង្គផង ២លានព្រះអង្គផង ដោយត្បូងរបស់ខ្ញុំព្រះករុណា ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព ។ ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឲ្យកំចាត់បង់ នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្ដីអន្តរាយទាំងឡាយ ជាអនេក ក៏ចូរឲ្យវិនាសទៅ កុំបីមានសេសសល់ឡើយ ។

## ព្រះបារមី៣០

ឥតិបិ ទាន បារមី សម្បន្នោ សោ ភគវា
ឥតិបិ ទាន ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ ទាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ សីល បារមី សម្បន្នោ សោ ភគវា
ឥតិបិ សីល ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ សីល បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ នេក្ខម្ម បារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្ម ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ បញ្ញា បារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញា ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ បញ្ញា បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ វិរិយ បារមី សម្បន្នោ សោ ភគវា

ឥតិបិ វិរិយ ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ វិរិយ បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ ខន្តី បារមី សម្បន្នោ សោ ភគវា

ឥតិបិ ខន្តី ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ខន្តី បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ សច្ច បារមី សម្បន្នោ សោ ភគវា

ឥតិបិ សច្ច ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ សច្ច បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ អធិដ្ឋាន បារមី សម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋាន ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ អធិដ្ឋាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ មេត្តា បារមី សម្បន្នោ សោ ភគវា

ឥតិបិ មេត្តា ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ មេត្តា បរមត្ថបារមី សម្បន្នោ សោ ភគវា ។

ឥតិបិ ឧបេក្ខា បារមី សម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខា ឧបបារមី សម្បន្នោ សោ ភគវា

ឥតិបិ ឧបេក្ខា បរមត្ថបារមី សម្បន្នោ សោ ភគវា តិ ។

# បត្តិទានគាថា

យង្កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចាមនសា

តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា

អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ

តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន ជានន្តិ

ទេវា គន្ត្វា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តា ហារ

ហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ

ប្រែៈ អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើដោយទ្វារទាំង៣ គឺកាយវាចា ចិត្ត អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សសួគ៌បាន សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបានចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយ សូមទេវតាទាំង

ឡាយអញ្ជើញ ទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ ៗ ចូរអនុមោទនាត្រេកអរ នឹងបុណ្យគេនោះចុះ សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយ ទៅឲ្យនេះចុះ ។

## អញ្ជើញពពួកទេវតា

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា សទ្ធម្មំ មុនិរាជស្ស

សុណន្តុ សគ្គមោក្ខទំ ភន្តេ ភគវា សុចិរ បរិនិព្វុតោ

ពុទ្ធោ មេ នាថោ ធម្មោ មេ នាថោ សង្ឃោ មេ នាថោ

ប្រែៈ ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្ដាប់នូវព្រះសទ្ធម្ម ជាធម៌អាចឲ្យនូវស្ថានសួគ៌ និងព្រះនិព្វាន (របស់ព្រះសម្មាសម្ពុទ្ធ) ជាស្ដេចនៃអ្នកប្រាជ្ញ ។

ព្រះដ៏មានបុណ្យជាម្ចាស់ដ៏ចម្រើន ព្រះអង្គទ្រង់ចូលបរិនិព្វាន ជាយូរអង្វែងហើយ ព្រះពុទ្ធជាម្ចាស់ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាម្ចាស់ជាទីពឹងនៃខ្ញុំ ព្រះសង្ឃជាម្ចាស់ជាទីពឹងនៃខ្ញុំ ។

# ទេវតាបកាសនគាថា

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ

ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា

ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរ

វចនំ សាធវោ មេ សុណន្តុ ។ ធម្មស្សវនកាលោ អយម្ភទន្តា

ធម្មស្សវនកាលោ អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភទន្តា

ប្រែះ ទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភុម្មទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ឰដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សា និងព្រៃញាត ស្បាត ឬទីស្រែចំការក្តី យក្ខនិងគន្ធព្វនិងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹក ទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា ក្នុងទីនេះ ពាក្យឯណាដែលជាពាក្យ ព្រះសក្យមុនីដ៏ប្រសើរ ដែលយើងនឹងសូត្រឥឡូវនេះ លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ដោយគោរព ។

បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់ព្រះធម៌ ។

# ពុទ្ធជ័យមង្គល

ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ គ្រីមេខលំ ឧទិតឃោ
រសេនមារំ ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ តន្តេជសា
ភវតុ តេ ជយមង្គលានិ ។

មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ ឃោរម្បនា ឡវក មក្ខមថទ្ធ
យក្ខំ ខន្តីសុទន្ត វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ
តេ ជយមង្គលានិ ។

នាឡាគិរី គជវរំ អតិមត្តភូតំ ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេក វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ
តេ ជយមង្គលានិ ។

ឧក្ខិត្តខគ្គ មតិហត្ថសុទារុណន្តំ ធាវន្តិយោ ជនបថង្គុលិមា
លវន្តំ ឥទ្ធីភិសង្ខ តមនោ ជិតវា មុនិន្ទោ តន្តេជសា
ភវតុ តេ ជយមង្គលានិ ។

កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា ចិញ្ចាយ ទុដ្ឋវចនំ ជនកាយ

មជ្ឈេ សន្តេន សោមវិធិនា ជិតវា មុនិន្ទោ តន្តេជសា

ភវតុ តេ ជយមង្គលានិ ។

សច្ចំ វិហាយមតិ សច្ចកវាទកេតុំ វាទាភិរោ បិតមនំ អតិអន្ធ

ភូតំ បញ្ញាបទី បជលិតោ ជិតវា មុនិន្ទោ តន្តេជសា

ភវតុ តេ ជយមង្គលានិ ។

នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ បុត្តេន ថេរភុជគេន ទមាប

យន្តោ ឥទ្ធូបទេស វិធិនា ជិតវា មុនិន្ទោ តន្តេជសា

ភវតុ តេ ជយមង្គលានិ ។

ទុគ្គាហទិដ្ឋិ ភុជគេន សុទដ្ឋហត្ថំ ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិ ពកា

ភិធានំ ញាណគទេន វិធិនា ជិតវា មុនិន្ទោ តន្តេជសា

ភវតុ តេ ជយមង្គលានិ ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា យោ វាចនោ ទិនទិនេ សរតេ

មតន្ទី ហិត្វាននេកវិ វិធានី ចុបទ្ទវានី មោក្ខំ សុខំ អធិគមេយ្យ

នរោ សបញ្ញោ ។

ប្រែៈ ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហាន្ធ និម្មិតដៃមួយពាន់

កាន់សស្ត្រាវុធនានា ។ ជិះគ្រីមេខលជាតិ កោញ្ចនាទខ្នរពសុធា

ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន ។ ដោយធម្មពិធី

ទានបារមីជាប្រធាន ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។

វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

ព្រះមុនិន្ទពិននាយក ផ្ចាញ់អាឡវកយក្សឃោឃៅ រឹងរូសមិនតាំងនៅ

ក្នុងខន្តីគុណសត្យា ។ រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា

ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។ ដោយព្រះពិធីញាណ

ទ្រង់ទូន្មានដោយខន្តី ញុំាងចិត្តអសុរី ឲ្យបង់ព្យុសចុះវន្ទា ។

វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះអាឡវកយក្ខហោង ។

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា គីរីវរគជា

ដ៏ហានក្លាចុះព្រេងព្រិច ។ សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច

មុតដូចចក្រុតពេជ ខ្លាំងដូចកម្មអសនី ។ ដោយព្រះពិធីស្រប់

ស្រោចទឹកអប់គឺបារមី មេត្តាព្រះជិនស្រី ញ៉ាំងដំរីឲ្យជ្រះថ្លា ។
វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះនាឡាគីរី ។

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ ផ្ចាញ់ចោរអង្គុលីមាល៍
មានកម្រងគឺម្រាមដៃ ។ នៃមនុស្សដែលគាត់កាត់ មកដោតចាក់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។ កាន់ដាវងាគ្រវី
ដេញព្រះមុនីសាស្តាចារ្យ ចម្ងាយផ្លូវកន្តារ កណ្ដាលព្រៃបីយោជនា ។
វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះឈ្នះអង្គុលិមាល៍ ។

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា អំពើធ្វើដូចជា
ស្ត្រីមានគភ៌ចាស់ចើសពោះ ។ យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។ រម្ងាប់ពាក្យចណ្ឌាល
នាកណ្ដាលជនប្រុសស្រី ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះសាស្តាឈ្នះចិញ្ចា ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា ផ្ចាញ់សច្ចៈកជា
និគ្រន្ថក្រៅពុទ្ធវិន័យ ។ អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។ បង្កើតម្ងរងងឹត
ដោយពោលឥតពាក្យទៀងត្រង់ ព្រះទ្រង់កំចាត់បង់ ដោយប្រទីបគឺបញ្ញា ។

រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ឈ្នះសច្ចកៈនិគ្រន្ថ ។

ព្រះមុនិន្ទពិនទ្រង់ញាណ ញ៉ាំងមោគ្គលានមានអំណាច ឲ្យប្លែងជានាគរាជ

ទៅទូន្មានព្យុសន៍ភូជង្គ ។ ឈ្មោះនន្ទោបនន្ទ ចិត្តមោហាន្ធរឿងឫទ្ធិរុង

ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។ គឺឲ្យឧបទេស

ឫទ្ធិវិសេសដល់មោគ្គលាន ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។

រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ព្រះភគវាឈ្នះនាគហោង ។

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា សំគាល់ថាអាត្មា

រុងរឿងដោយគុណបរិសុទ្ធ ។ ដៃកាន់អសិរពិស គឺចិត្តទ្រឹស្តដ៏មុះមុត

កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។ ទ្រង់ឈ្នះដោយវិធី

ឱសថវីសេសសម្រាន្ត ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។

រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា ដោយតេជះជយា ឈ្នះព្រហ្មាឥតមានហ្មង ។

យោ នរោ ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល ឧស្សាហ៍សាងទាននៃសីល

សូត្ររំលឹកព្រះធម៌ថ្លៃ ។ គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ ខំសូត្រសព្វ ៗ ថ្ងៃ

កើតមង្គលជានិរន្តរ៍ ។ សោ នរោ រីជននោះ បានរដោះរោគអាសន្ន ឧបទ្រពអនេកលន់

មានប្រការផ្សេង ៗ ផង ។ នឹកដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង

លែងទុក្ខទាំង៤កង ដោយពុទ្ធជ័យមង្គលនេះ ។

# សូត្រឧទ្ទិសកុសលច្រូចទឹក

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា អាចរិយូបការា

ច មាតាបិតា ច ញាតិកា (បិយា មមំ) សុរិយោ ចន្ទិមា

រាជា គុណវន្តា នរាបិ ច ព្រហ្មារា ច ឥន្ទ្រា ច លោកបាលា

ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច

សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ សុខញ្ច

តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។

ប្រែៈ ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ អាចារ្យទាំងឡាយ មានឧបការៈ មាតាបិតានឹងញាតិទាំងឡាយ (មាតាបិតាជាទីស្រឡាញ់) ព្រះអាទិត្យ ព្រះចន្ទ ព្រះរាជា នរជនអ្នកមានគុណទាំងឡាយ ព្រះព្រហ្មនិងមារាធិរាជ ព្រះឥន្ទទាំងឡាយ លោកបាលមហារាជ និងទេវតាទាំងឡាយ ព្រះយមរាជនិងមនុស្សទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរនឹងគ្នាក្តី សូមឲ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយ ដែលខ្ញុំបានកសាងសន្សំហើយ ចូរឲ្យនូវសេចក្តីសុខទាំង៣ប្រការ សូមឲ្យអ្នកទាំងឡាយបានដល់នូវ អមតមហានិព្វាន ឲ្យបានឆាប់រួសរាប់ទាន់សេចក្តីប្រាថ្នាហោង ។

ឥមិនា បុញ្ញកម្មេ ឥមិនា ឧទ្ទិសេន ច ខិប្បាហំ សុលភេ ចេវ តណ្ហុបាទានឆេទនំ យេ សន្តា នេ ហីនា ធម្មា យាវ និព្វាន តោ មមំ នស្សន្តុ សព្វទា យេវ យត្ថ ជាតោ ភវេ ភវេ ឧជុចិត្ត សតិបញ្ញា សល្លេខោ វិរិយម្ហិនា មារា លភន្តុ មោកាសំ (នោកាសំ) កាតុញ្ច វិរិយេសុ មេ ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

ប្រែៈ ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឲ្យខ្ញុំបានដោយងាយយ៉ាងរួសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្តាច់បង់ នូវតណ្ហានិងឧបាទាន ធមិទាំងឡាយណា ជាធមិថោកទាប គឺអកុសលធមិនៅក្នុងសន្តានចិត្តខ្ញុំ សូមឲ្យវិនាសបាត់រៀងរាល់កាលទៅ រហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន បើខ្ញុំអន្ទោលទៅចាប់កំណើត ក្នុងភពតូចនិងភពធំ ណា ៗ សូមឲ្យខ្ញុំជាបុគ្គលមានចិត្តត្រង់មានសតិបញ្ញាមានចិត្តស្អាតផូរផង់ ទាំងសូមឲ្យមានព្យាយាមផង មារទាំងឡាយចូរកុំបាននូវឱកាស ដើម្បីធ្វើឲ្យខូចព្យាយាមខ្ញុំឡើយ ព្រះពុទ្ធដូចជាប្រទីបឬកោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធមិជាទីពឹង ដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធ ក៏ជាទីពឹងនៃខ្ញុំដែរ ដោយឧត្តមានុភាព នៃព្រះពុទ្ធ ព្រះធមិ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាស ចូលមកជ្រៀតជ្រែកឡើយ ។

# វិធីសមាទានសីល៥

ឧកាស មយំ (ម្នាកឯងថាអហំ) ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ បញ្ចសីលានិ យាចា ម (ម្នាក់ឯងថាមិ)

ទុតិ យម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

បញ្ចសីលានិ យាចា ម

តតិ យម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ

បញ្ចសីលានិ យាចា ម

**ប្រែ:** សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា (ទាំងឡាយ) សូមនូវសីលទាំងឡាយ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា (ទាំងឡាយ) សូមនូវសីលទាំងឡាយ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគំរប់២ដងផង ជាគំរប់៣ដងផង ។

# ការទទួលសីល

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ប្រែៈ កិរិយានមស្ការ ថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

ពុទ្ធំ សរណំ គច្ឆាមិ

ប្រែៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ។

ធម្មំ សរណំ គច្ឆាមិ

ប្រែៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក ។

សង្ឃំ សរណំ គច្ឆាមិ

ប្រែៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ប្រែៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ជាគំរប់២ដងផង។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ប្រែៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក ជាគំរប់២ដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ប្រែ: ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ជាគំរប់២ដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ប្រែ: ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ជាគំរប់៣ដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ប្រែ: ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក ជាគំរប់៣ដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ប្រែ: ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ជាគំរប់៣ដងផង ។

ហើយលោកពោលថា:

តិសរណគ្គនំ បរិបុណ្ណំ

ប្រែ: កិរិយាកាន់យកនូវ ព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណេះ ។

ឧបាសកទទួលថា:

អាម ភន្តេ

ប្រែ: ករុណាលោកម្ចាស់ ។

លោកឲ្យនិច្ចសីលជាបច្ចេកសមាទានថា:

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែះ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើនូវសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែះ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬដោយវាចា ។

កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែះ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែះ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែះ ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

លោកសូត្ររំលឹកថាៈ

ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ

ប្រែ: អ្នក (ទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយ៥នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ អស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា:

អាម ភន្តេ ករុណាលោកម្ចាស់ ។

លោកសម្ដែងអានិសង្សនៃសីលថា:

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ

យន្តិ តស្មា សីលំ វិសោធយេ

ប្រែ: សត្វទាំងឡាយ បានទៅកាន់ស្ថានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជំរះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា:

សាធុ ប្រពៃ ។

# ពាក្យអារាធនាព្រះសង្ឃចម្រើនព្រះបរិត្ត

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វទុក្ខវិនាសាយ

បរិត្តំ ព្រូថ មង្គលំ ។

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វភយវិនាសាយ

បរិត្តំ ព្រូថ មង្គលំ ។

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វរោគវិនាសាយ

បរិត្តំ ព្រូថ មង្គលំ ។

ប្រែៈ សូមព្រះករុណាទាំងឡាយ ចម្រើននូវព្រះបរិត្ត ជាជ័យមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឲ្យបានសម្រេច នូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំង ទុក្ខ - ភ័យ - រោគ ទាំងអស់ឲ្យវិនាសបាត់ទៅ ។

# មង្គលសូត្រ

ឯវមេ សុត្តំ

គឺខ្ញុំ (ឈ្មោះអានន្ទ បានស្តាប់មកហើយយ៉ាងនេះថា)

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស

អារាមេ

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន ជាអារាមរបស់អានាថបណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា

កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ

លំដាប់នោះឯង ទេវតាអង្គ១ កាលដែលវេលារាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អមញ្ញាំងវត្តជេតពន ជុំវិញទាំងអស់ឲ្យភ្លឺស្វាង ហើយព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះអង្គដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ

ឯកមន្តំ ឋិតា ខោសា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ

កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគដោយពាក្យជាគាថា (យ៉ាងនេះ) ថា

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ អាកង្ខមានា សោត្ថានំ

ព្រូហិ មង្គលមុត្តមំ

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្ដីសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តា សំដែងប្រាប់នូវមង្គលដ៏ឧត្តម (ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែង តបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថា យ៉ាងនេះថា)

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា បូជា ច បូជនិយានំ

ឯតម្មង្គលមុត្តមំ

កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គល ដែលគួរបូជាទាំងឡាយ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម ។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា អត្តសម្មាបណីធិ ច

ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យ ទុកហើយក្នុងកាលមុន១ កិរិយាដំកល់ខ្លួនដោយប្រពៃ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិត្តោ សុភាសិតា ច យា

វាចា ឯតម្មង្គលមុត្តំ

ភារៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន១ សិល្ប៍សាស្ត្រគឺសេចក្តីឆ្លៀវឆ្លាស់ក្នុងហត្ថកម្ម របស់អ្នកបួសនិងគ្រហស្ថ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ អនាកុលា ច កម្មន្តា

ឯតម្មង្គលមុត្តមំ

កិរិយាបំរើនូវមាតា១ កិរិយាបំរើនូវបិតា១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា១ ការងារទាំងឡាយដែលមិនច្របូកច្របល់១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតិកានញ្ច សង្គហោ អនវជ្ជានិ កម្មានិ

ឯតម្មង្គលមុត្តមំ

កិរិយាបរិច្ចាគទាន១ កិរិយាប្រព្រឹត្តនូវធម៌១ សេចក្តីសង្គ្រោះ ដល់ញាតិទាំងឡាយ១ ការងារទាំងឡាយដែលមិនមានទោស១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ អប្បមាទោ ច ធម្មេសុ

ឯតម្មង្គលមុត្តមំ

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា កាលេន ធម្មស្សវនំ

ឯតម្មង្គលមុត្តមំ

សេចក្តីគោរពចំពោះបុគ្គល ដែលគួរគោរព១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន១ កិរិយាស្តាប់នូវធមិតាមកាល១ ទាំង៥នេះ ជាមង្គលដ៏ឧត្តម ។

ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ កាលេន ធម្មសាកច្ឆា

ឯតម្មង្គលមុត្តមំ

សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែល គេប្រដៅបានដោយងាយ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ១ ធម្មសាកច្ឆាគឺកិរិយា សន្ទនាទៅវិញទៅមក នូវធមិតាមកាល១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ និព្វានសច្ឆិកិរិយា ច

ឯតម្មង្គលមុត្តមំ

សេចក្តីព្យាយាមដុតនូវបាបធមិ១ កិរិយាប្រព្រឹត្តនូវធមិដ៏ប្រសើរ១ កិរិយាឃើញនូវអរិយសច្ចៈទាំងឡាយ១ កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ អសោកំ វិរជំ ខេមំ

ឯតម្មង្គលមុត្តមំ

ចិត្តនៃបុគ្គលឯណា ដែលលោកធមិទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ១ មិនមានសេចក្តីសោក១ មានធុលីគឺរាគៈទៅប្រោសហើយ១ ជាចិត្តក្សេមក្សាន្ត១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម ។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ សោត្ថឹ គច្ឆន្តិ

តន្តេសំ មង្គលមុត្តមន្តិ

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសេរីស្ហួស្តីក្នុងទីទាំងពួង (ម្នាលទេវតា ចូរអ្នកប្រកាន់ជឿថា) មង្គលទាំង៣៨ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្ស ទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

# មាតិកាធម៌


ទំព័រ ១- ថ្វាយគ្រឿងសក្ការៈព្រះត្រ័យរត្ន

ទំព័រ ២ ដល់ ទំព័រ ៥- នមស្ការព្រះពុទ្ធរតនៈ

ទំព័រ ៥ ដល់ ទំព័រ ៧- នមស្ការព្រះធម្មរតនៈ

ទំព័រ ៨ ដល់ ទំព័រ ១១- នមស្ការព្រះសង្ឃរតនៈ

ទំព័រ ១១- ធម៌សូមបុណ្យកងកុសល

ទំព័រ ១២- វន្ទាមិចេតិយំ

ទំព័រ ១៣- សុភមង្គលកថា ហោន្តុ សព្វំសុមង្គលំ

ទំព័រ ១៤ ដល់ ទំព័រ ១៥- ធម៌ផ្សាយមេត្តា សព្វេ បុរត្ថិមាយ

ទំព័រ ១៦- ធម៌រំលឹកគុណ តេជះខ្ញុំសាង

ទំព័រ ១៦ ដល់ ទំព័រ ១៧- ខមាបនគាថា យេកេច ខុទ្ទកា បាណា

ទំព័រ ១៧ ដល់ ទំព័រ ១៨- អនុមោទនារក្ខាយាចនគាថា អាកាសដ្ឋា ច ភូម្មដ្ឋា

ទំព័រ ១៨ ដល់ ទំព័រ ១៩- ជយបរិត្តគាថា ជយន្តោ ពោធិយា មូលេ

ទំព័រ ១៩ ដល់ ទំព័រ ២១- សម្ពុទ្ធេ

ទំព័រ ២១ ដល់ ទំព័រ ២៣- ព្រះបារមី៣០ ឥតិបិទាន

ទំព័រ ២៤ ដល់ ទំព័រ ២៥- បត្តិទានគាថា យំកិញ្ចិ កុសលកម្មំ

ទំព័រ ២៥- អញ្ជើញពពួកទេវតា សមន្តា ចក្កវាឡេសុ

ទំព័រ ២៦- ទេវតាបកាសនគាថា សគ្គេ កាមេ ច រូបេ

ទំព័រ ២៧ ដល់ ទំព័រ ៣១- ពុទ្ធជយមង្គល ពាហុំ សហស្សមភិនិម្មិតសា

ទំព័រ ៣២ ដល់ ទំព័រ ៣៣- សូត្រឧទ្ទិសកុសលព្រួចទឹក ឥមិនា បុញ្ញកម្មេ

ទំព័រ ៣៤ ដល់ ទំព័រ ៣៩- ពិធីសមាទានសីល៥ ឧកាស មយំ ភន្តេ

ទំព័រ ៤០- ពាក្យអារាធនាព្រះសង្ឃចម្រើនព្រះបរិត្ត វិបត្តិប្បដិពាហាយ

ទំព័រ ៤១ ដល់ ទំព័រ ៤៥- មង្គលសូត្រ ឯវមេ សុត្តំ

Visuddhi7.com

ចងក្រងឡើងនិងចែកជូនជាធម្មទានដោយ ជា- ហេង

http://www.visuddhi7.com/

E-mail: Tonlebet63@aol.com